ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : 0៥៤/២១ ក.ប/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងជ្រើសរើសក្របខណ្ឌថ្មី មន្ត្រីគ្រប់គ្រងរដ្ឋបាលសម្រាប់ឆ្នាំ២០២១ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ ឱ្យបានជ្រាបថា **លទ្ធផលជាប់ជាស្ថាពរ និងជាប់បម្រុង នៃការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីកាលពី ថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នឹងបិទប្រកាសនៅទីស្តីការក្រសួង និងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នាថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៩:០០នាទីយប់។**

ដោយឡែកចំពោះបេក្ខជន ដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវមកបង្ហាញខ្លួន និងចូលរួមប្រជុំស្តាប់ការណែនាំ និងបំពេញឯកសារផ្សេងៗជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក **នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៩:០០នាទីព្រឹក នៅសាលប្រជុំ B ទីស្តីការក្រសួង។**

❖ **<u>បញ្ជាក់</u>៖ គណៈកម្មការរៀបចំការប្រឡង សូមរក្សាសិទ្ធិក្នុងការជ្រើសរើសបេក្ខជនជាប់បម្រុងជំនួស ក្នុងករណីបេក្ខជនជាប់ជាស្ថាពរ មិនមកបង្ហាញដោយគ្មានមូលហេតុសមរម្យ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម បេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២១

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជា**

**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ហេង សួរ**

**<u>ព័ត៌មានបន្ថែមសូមទំនាក់ទំនង:</u>**

- លោក គួយ គៀន ០៧៧ ៥១៨ ៥១១/០៩៦ ៨៦៧ ២២៥៥
- កញ្ញា លី យ៉ាណា ០១១ ៨២៦ ១៦៥/០៨១ ៨០៥ ០៣៦